អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មានពីអង្គភាពគាំពារការពារក្តី

អង្គភាពគាំពារការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចាត់តាំងលោក លីវ សុវណ្ណា ជាសហមេធាវីជាតិទីពីរដើម្បីតំណាងលោក នួន ជា នៅក្នុងសំណុំរឿង ០០២/០២។

លោក លីវ សុវណ្ណា គឺជាមេធាវីកម្ពុជាមួយរូបដែលមានបទពិសោធន៍ជាង ២០ ឆ្នាំ នៅក្នុងការប្រកបវិជ្ជាជីវៈឯកជន។ ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ គាត់គឺជាអ្នកប្រឹក្សាច្បាប់នៅក្នុងក្រុមមេធាវីការពារក្តីលោក នួន ជា រាប់បញ្ចូលទាំងការងារនៅក្នុងអំឡុងពេលជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ផងដែរ។ បច្ចុប្បន្ននេះ គាត់ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការរងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ គាត់ក៏ជាសាស្ត្រាចារ្យនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីផងដែរ។ លោក លីវ សុវណ្ណា មានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសាកលវិទ្យាល័យឯកទេសនៃកម្ពុជា និងបរិញ្ញាបត្រច្បាប់(ជំនាន់ទីពីរ)ពីសាលាបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា។

លោក លីវ សុវណ្ណា នឹងធ្វើការរួមគ្នាជាមួយនឹងលោក សុន អរុណ សហមេធាវីកម្ពុជា និងលោកស្រី Doreen CHEN សហមេធាវីបរទេស ដើម្បីតំណាងលោក នួន ជា នៅចំពោះមុខ អ.វ.ត.ក។ ចំពោះការចាត់តាំងនេះ អង្គភាពគាំពារការពារក្តី បានពិចារណាតាមបំណងរបស់លោក នួន ជា និងការលះបង់សិទ្ធិទំនាស់ផលប្រយោជន៍ទាំងអស់ដែលមានជាធរមាន។



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh